ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែធ្នូ ឆ្នាំ២០១៤

នៅក្នុងខែធ្នូ ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១.សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-ទទួលជួបសម្តែងការគួរសមជាមួយឯកឧត្តម **TRUONG TAN SANG** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ជូនគណៈកម្មការជំនាញព្រឹទ្ធសភាចំនួន០១ច្បាប់

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ចំនួន០២ច្បាប់ និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២ច្បាប់

-ចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន១៨លិខិត ។

**១.២.ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក កិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជូនគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះរាជដំណាក់សេរីមង្គលព្រះបរមរាជវាំង



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម **ជៀង តិនសាង** ប្រធានរដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសដែលឯកឧត្តម ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

-ទទួលជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូ ក្រុមប្រឹក្សាសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ដឹកនាំដោយឯកឧត្តម Evgeny Serebrennikov អនុប្រធានទី១ គណៈកម្មការ ការពារជាតិ និងសន្តិសុខជាតិនៃសភាសហព័ន្ធ សហព័ន្ធរុស្ស៊ី នៅវិមានព្រឹទ្ធសភា

-ទទួលជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃគណៈកម្មាធិការ ជាតិសភាប្រឹក្សានយោបាយប្រជាជនចិនដឹកនាំឯកឧត្តម Chen Xiaoguang អនុប្រធានសភា ប្រឹក្សានយោបាយប្រជាជនចិន នៅវិមានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ ជាកិត្តិយសជូនគណៈប្រតិភូជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិសភាប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយឯកឧត្តម Chen Xiaoguang អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា

-អញ្ជើញចុះជួបសំណេះសំណាល ជាមួយអាជ្ញាធរឃុំបឹងព្រាវ ក្នុងស្រុកស្រែអំបិល ខេត្តកោះកុង, អាជ្ញាធរស្រុកកំពុងសិលា ខេត្តព្រះសីហនុ, អាជ្ញាធរស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ, អាជ្ញាធរខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ដើម្បីស្វែងយល់ និងក្តាប់សភាពការណ៍នៃការអនុវត្តន៍ កម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលព្រមទាំង លទ្ធផលនៃការអនុវត្តន៍គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ ក្រោមជាតិ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០៤ច្បាប់។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើក កិច្ចប្រជុំពេញអង្គ ព្រឹទ្ធសភាចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីយាងព្រះរាជដំណើរ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** យាងចូលរួមប្រជុំកំពូលព្រះពុទ្ធសាសនាពិភពលោក លើកទី៦ ប្រទេសជប៉ុន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួបសម្តែងការគួរសមរវាង ប្រធានរដ្ឋនៃសធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយឯកឧត្តម **សាយ ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ជូនគណៈប្រតិភូចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

-អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីថ្ងៃសុន្ទរកថាបើកសិក្ខាសាលាស្តីពី " ការប្រើប្រាស់សិទ្ធិនិងច្បាប់ " អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ

-អញ្ជើញចូលរួមជាកិត្តិយស ក្នុងជំនួបសំណេះសំណាលរវាងគណៈប្រតិភូសមាគមមិត្តកម្ពុជា-ចិន នៃទីក្រុងប៉េកាំង

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ជូនគណៈប្រតិភូរុស្ស៊ី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន ៧០ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៤លើក ដើម្បី៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០២ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំវិសាមញ្ញ និងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី " ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ " ទៅក្នុងរបៀបវារៈប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ។

២.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ ព្រឹទ្ធសភា នីតិកាលទី៣ ។

៣.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី " ចរាចរណ៍ផ្លូវគោក " ។

៤.កំណត់កាលបរិច្ឆេទរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី៦ ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំវិសាមញ្ញចំនួន០១លើក ដើម្បី៖**

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី " ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ

២០១៥"។

**៤.សម័យប្រជុំពេញអង្គចំនួន០២លើក ដើម្បីៈ**

១.ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៥ និងលើកទី៦ ព្រឹទ្ធសភា នីតិកាលទី៣ ។

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី" ចរាចរណ៍ផ្លូវគោក"។

**៥. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែធ្នូនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាម តួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៥.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០២

**៥.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន១២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៤ករណី និងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០១ករណី

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ស្តីពី " ដំណើរទស្សនកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងសហគមន៍ខេត្តបន្ទាយមានជ័យ មកស្ថាប័នព្រឹទ្ធសភា " និង "គម្រោងរៀបចំវគ្គបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ប៉ៃលិន សម្រាប់ឆ្នាំ២០១៥

-ប្រជុំស្តីពី "ការបង្ហាញច្បាប់ប្រឆាំងអំពើពុករលួយ "

-ប្រជុំពិភាក្សាអំពី ការបែងចែក នៃការប្រើប្រាស់កញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០១៥

-ប្រជុំពិភាក្សាជាមួយមន្ត្រីវិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីត្រៀមចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពី" ជោគជ័យក្នុងការកាត់បន្ថយមេរោគអេដស៍,ជំងឺអេដស៍ នៅកម្ពុជា"

-ចូលរួមសន្និសីទផ្សព្វផ្សាយច្បាប់ស្តីពី អង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

-បើកអង្គសិក្ខាសាលាថ្នាក់ជាតិស្តីពី" គ្រឿងស្រវឹង និងព្រះពុទ្ធសាសនា"

-ចូលរួមអង្គសិក្ខាសាលាដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូស្តីពី" ការប្រើប្រាស់សិទ្ធិ និងច្បាប់"

-ចូលរួមក្នុងបាឋកថាស្តីពី អាស៊ានទស្សនវិស័យអូស្ត្រាលី អតីតកាល បច្ចុប្បន្ន និងអនាគត

-បទបង្ហាញរបស់អង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH) ស្តីពីការជ្រៀតជ្រែករបស់ឧស្សាហកម្មថ្នាំជក់ និងលទ្ធផលនៃការស្ទង់មតិយុវជន ស្តីពីវិធានការត្រួតពិនិត្យថ្នាំជក់

-ជួបពិភាក្សាការងារជាមួយលោក Andreas von Gall អ្នកវាយតម្លៃឯករាជ្យ និងជាអតីតអគ្គសវនកររង នៃរដ្ឋ Hassen ប្រទេសអាល្លឺម៉ង់ ដើម្បីពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តគម្រោង GIZ គាំទ្រអាជ្ញាធរសវនកម្មជាតិ (GIZ-NAA) រយៈពេលពីរឆ្នាំចុងក្រោយក្នុងការជួយគាំទ្រដល់គណៈកម្មការទី២ព្រឹទ្ធសភា

-ជួបពិភាក្សាការងារជាមួយលោកស្រី Catherine M.Cecil ទីប្រឹក្សាឯករាជ្យវិទ្យាស្ថានសភាកម្ពុជា(PIC)

-ជួបពិភាក្សាការងារជាមួយតំណាងអង្គការ (GIZ)ស្តីពី ថវិកាឃុំ-សង្កាត់ និងសវនកម្មនៅឃុំ-សង្កាត់

-ជួបពិភាក្សាការងារជាមួយឯកឧត្តម **ទា ផល្លា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ស្តីពី ការកាត់បន្ថយ ការការពារ និងការព្យាបាលជំងឺអេដស៍ នៅកម្ពុជា

-អនុញ្ញាតឲ្យលោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា និងលោកស្រី **លឹម សុខជា** នាយិកាប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងតំណាងអង្គការផ្សេងៗមួយចំនួនទៀត ជួបពិភាក្សាការងារ ដើម្បីពិនិត្យអនុសាសន៍នានា ដែលជាប់ពាក់ព័ន្ធទៅនឹងសេចក្តីព្រាងច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ១១៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខអាជីវករដែលរងគ្រោះដោយសារភ្លើងឆេះផ្សារ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩២លើក។

**៥.៣. មុខងារព័ត៌មាន / ត្រួតពិនិត្យ**

-គណៈកម្មការទី២ ចុះបេសកកម្មដើម្បីសិក្សាស្វែងយល់អំពី ដំណើរការប្រព្រឹត្តិទៅរបស់គណៈបញ្ជាការសន្តិសុខជាតិវៀតណាម នៅខេត្តមណ្ឌលគិរី និងខេត្តដាក់ណុង ប្រទេសវៀតណាម។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ជា ជេដ្ឋ** បានដឹកនាំគណៈប្រតិភូសមាជិកព្រឹទ្ធសភាអញ្ជើញទៅ ចូលរួមសន្និសីទស្តីពី វេទិកាអង្គការក្រៅរដ្ឋាភិបាលឆ្នាំ២០១៤-២០១៥ នៅខេត្តដុងណៃ ទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-ឯកឧត្តម **ឈិត តឹមយាត** បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គលើកទី៧ របស់មហាសន្និបាតសភាអាស៊ី (APA) នៅទីក្រុងឡាហ័រ នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ។

-លោកជំទាវ **ពុំ ស៊ីចាន់** បានអញ្ជើញចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពី " ការទប់ស្កាត់មេរោគអេដស៍ នៅប្រទេសវៀតណាម" នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-ឯកឧត្តម **ហុង សុខហួរ**, ឯកឧត្តម **ម៉ម ប៊ុននាង**, ឯកឧត្តម **សេង ម៉ារឌី**, ឯកឧត្តម **ម៉ែន ស៊ីផាន់** និងឯកឧត្តម **សោ ចាន់ដេត** បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សានៅទីក្រុងប៊ែកឡាំង ប្រទេសអាល្លឺម៉ង់ ។៚

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ